1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣*៤៤

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ២៥៩

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩

**សាលដីកា**

លេខៈ ០៤

ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០១

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១

ដោយមានសមាសភាពដូចតទៅ ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | ប៉ែន | ស៊ិន | ជាចៅក្រមរបាយការណ៍ |
| ៣-លោក | វៀល | មូន | ជាចៅក្រម |
| ៤-លោក | យស់ | សូខឿន | ជាចៅក្រម |
| ៥-លោក | គង់ | ភីរុន | ជាចៅក្រម |

ក្រឡាបញ្ជី

អ្នកស្រី **ឆួន ចន្ថា**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការរដ្ឋប្បវេណីលេខ ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៦២៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ រវាង ៖

ដើមចោទឈ្មោះ **ម៉ក់ ងាក់** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិមេម៉ាយ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះហុង ឈាង (រ) ម្តាយឈ្មោះអ៊ុយ ខេង(រ) ប្រពន្ធឈ្មោះយាប វី មានកូន៣នាក់ ។

ចុងចំលើយឈ្មោះតែ **ឈុនឡាង** (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិបឹងកុក១ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ តែ គិត(ស) ម្តាយឈ្មោះ ម៉ៅ លាយ(រ) ប្តីគ្មាន មានកូន០២នាក់ ។

**កម្មវត្ថុបណ្តឹង** ៖ ប្តឹងទាមទាររថយន្តកាម៉ាស់មួយគ្រឿង

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៩ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោក ប៉ាក់ ង៉ាក់ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៣-០៧-១៩៩៧ របស់ឈ្មោះ ប៉ាក់ ង៉ាត់ ប្តឹងសុំសិទ្ធិកាន់កាប់រថយន្តកាំម៉ាស់មួយគ្រឿងទាំងក្បាលទាំងរ៉ឺម៉កសណ្តោង ដែលឈ្មោះ ហាក់ យ៉ឹម និង ប្រពន្ធឈ្មោះ ហ៊ូ នាង ដាក់បញ្ចាំឱ្យខ្លួនក្នុងចំនួន២៥.០០០ដុល្លាអាមេរិក ពីឈ្មោះតែ ឈុនឡាង ដោយសំអាងហេតុថា ឈ្មោះ តែ ឈុនឡាង បានទិញរថយន្តនេះពីឈ្មោះ ហាក់យ៉ឹម និងប្រពន្ធឈ្មោះ ហ៊ូ នាង ដែលអ្នកទាំងពីរនេះដាក់បញ្ចាំឱ្យខ្លួនតាំងពីថ្ងៃទី០៩-១២-១៩៩៦ ជាប្រាក់ចំនួន ២៥.០០០ដុល្លាអាមេរិក ក្នុងចំនួនទឹកប្រាក់ខ្ចីពីខ្លួន ៧៥.០០០ដុល្លា រថយន្តដាក់បញ្ចាំឱ្យខ្លួនលេខ យ-០០២១ ភពា លេខម៉ាស៊ីន ០០២០៣៩១ លេខសាក់ស៊ី ០៤.៨៩ លេខតួ០៤៣០៧៥៧ ស្រាប់តែឃើញនៅលើដៃឈ្មោះតែ ឈុនឡាង ដោយមានធ្វើលិខិតអន្តរាគមន៍ខេត្តកំពង់ចាម ឱ្យប្រើប្រាស់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣៨ "ក" ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ប៉ាក់ ង៉ាក់ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ១៩៩៧ ដែលប្តឹងសុំសិទ្ធិកាន់កាប់រថយន្តកាំម៉ាស់លេខ ០០២១ ពីចុងចំលើយឈ្មោះតែ ឈុនឡាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។ (មិនស្របតាមមាត្រា ៦៤ នៃក្រឹត្យច្បាប់លេខ ៣៨ កិច្ចសន្យាស្តីពីការបញ្ចាំចលនវត្ថុ ) ។

២-ទទួលពាក្យបណ្តឹងសារត្រឡប់របស់ចុងចំលើយឈ្មោះ តែ ឈុនឡាង នៅពេលសវនាការសុំអោយតុលាការទទួលស្គាល់ខ្លួនជាម្ចាស់រថយន្តកាំម៉ាស់លេខ ០០២១ ភពា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។

៣-ទទួលស្គាល់ប័ណ្ណសំគាល់យានយន្ត ម៉ាកកាម៉ាស់ ប្រភេទដឹកទំនិញពាក់ផ្លាកលេខ យ-០០២១ ចុះថ្ងៃទី០៩-០៥-៩៧ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលមានម្ចាស់កម្មសិទ្ធិឈ្មោះតែ ឈុនឡាង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។ (តាមមាត្រា ៤១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យានៃការលក់) ។

៤-ចាប់ពីពេលនេះតទៅឈ្មោះតែ ឈុនឡាង មានសិទ្ធិគ្រប់គ្រង ប្រើប្រាស់អាស្រ័យផលនិងចាត់ចែងលើរថយន្តកាម៉ាស់ពាក់ផ្លាកលេខ យ-០០២១ ភពា លេខម៉ាស៊ីន០០២០៣៩១ លេខតួ០៤៣០៧៥៧ ទៅតាមច្បាប់កំណត់ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ នៅពេលដែលសាលក្រមចូលស្ថាពរបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%ស្មើ $\frac{1 \times 25.000\$}{100} = 2500$ ដុល្លាអាមេរិក = ៧៥០.០០០ដុល្លាអាមេរិកដែលត្រូវដាក់ចូលថវិការដ្ឋ ៨០% និង បានរង្វាន់ក្រឡាបញ្ជី

ទូទាំងប្រទេស២០% ។ ប្រាក់នេះឱ្យចុងចំលើយបង់ជាមុន ទើបបង្គាប់ឱ្យដើមចោទសងវិញជាក្រោយ ។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង ចុងចំលើយ ភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៦២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះប៉ាក់ ង៉ាក់ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៣៨ "ក" ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបៀបលេខ៣៨ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីដូចតទៅ :

បញ្ចូលឈ្មោះហាក់ យីម អាយុ៥១ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១០ ផ្លូវលេខ១៨១០ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ជាតតិយជនខាងចុងចំលើយ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-១០-១៩៩៧ របស់ប៉ាក់ ង៉ាក់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខ្វះសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៣៨"ក"ចុះថ្ងៃទី២៣-៩-១៩៩៧ របស់តុលាខេត្តកំពង់ចាម ទុកជាបានការ ។

៣-សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ .

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី កំបាំងមុខតតិយជនឈ្មោះ ហាក់ យីម បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោក ប៉ាក់ ង៉ាក់ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចំលើយរបស់ឈ្មោះប៉ាក់ ង៉ាក់ នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល មកពីសាលាឧទ្ធរណ៍សំរេចសេចក្តី មិនត្រឹមត្រូវឱ្យខ្លួន ព្រោះថា : តែ ឈុនឡាង បានទិញរថយន្តពីឈ្មោះឃឹម ហាក់ និងប្រពន្ធឈ្មោះហូ នាង ដែលដាក់បញ្ចាំឱ្យខ្លួនក្នុងចំនួនទឹកប្រាក់២៥.០០០ ដុល្លាអាមេរិក ក្នុងចំនួនទឹកប្រាក់ ៧៥.០០០ដុល្លាអាមេរិក តាំងពីថ្ងៃទី ០៩-១២-១៩៩៦ ។ រឿងនេះខ្លួនបានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តក្រចេះ តុលាការខេត្តក្រចេះ ក៏បានសំណុំរឿងនេះមកតុលាការខេត្តកំពង់ចាម ជាអ្នកដោះស្រាយវិញ ។ ព្រោះខ្លួនជាម្ចាស់បំណុលដូចគ្នា សុំឱ្យតុលាការកំពូល មេត្តាចែកប្រាក់នេះ ជាពីរចំណែកស្មើគ្នា ព្រោះយើងជាម្ចាស់បំណុលដូចគ្នា ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់លោក ប៉ាក់ ង៉ាក់
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោកប៉ាក់ង៉ាក់ បានធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា តុលាការថ្នាក់ក្រោមមុននឹងសំរេចរឿងនេះ ដល់អង្គសេចក្តី បានធ្វើការស៊ើបសួរត្រឹមត្រូវតាមនីតិវិធីហើយ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចំលើយឈ្មោះ តែ ឈុនឡាង មានសិទ្ធិគ្រប់គ្រងប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើរថយន្តកាម៉ាស់ពាក់ផ្លាកលេខឃ-០០២១ ភពៗ លេខម៉ាស៊ីន ០០២០៣៩១ លេខតួ ០៩៣០៧៥៧ ទៅតាមច្បាប់ ។ ហើយលោកប៉ាក់ ង៉ាក់ ពុំមានសិទ្ធិឡើងជាម្ចាស់នៃវត្ថុបញ្ចាំបានឡើយ តាមមាត្រា ៧១ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា ការលើកឡើងក្នុងសារណារបស់លោក ប៉ាក់ ង៉ាក់ សុទ្ធតែជារឿងនៃអង្គហេតុ ដែលតុលាការថ្នាក់ក្រោម បានពិចារណារួចហើយ ។

- យល់ឃើញថា អ្នកស្រី តែ ឈុនឡាង ពុំបានធ្វើសារណាការពាររឿងក្តីរបស់អ្នកស្រីជូនមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខលោកប៉ាក់ ង៉ាក់ កំបាំងមុខ**

**អ្នកស្រី តែ ឈុនឡាង ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោក ប៉ាក់ ង៉ាក់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦-០៥-១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រដែលលោកប៉ាក់ ង៉ាក់បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រ សរុប១៩.០០០រ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តកំពង់ចាម ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០១ ។